# របៀបប្រើឧបករណ៍ការពារ មូសខាំទាំងបីមុខ







សូមយកឧបករណ៍ការពារមូសខាំទាំងអស់ទៅ ជាមួយ ពេលអ្នកទៅព្រៃ។ ស្លៀកសម្លៀកបំពាក់ ដៃជ្រលក់ថ្នាំ លាបថ្នាំការពារមូសខាំលើស្បែក របស់អ្នក ហើយយក ភើករបស់អ្នកទៅព្យួរនៅ ជិតអ្នក នៅពេលអ្នកកំពុងសម្រាក ឬគេង។


Malaria Elimination Initiative

UCSF

Institute for Global Health Sciences

Australian Government

Department of Foreign Affairs and Trade

IVCC

Building Partnerships
Creating Solutions
Saving Lives

# លក្ខខណ្ឌពិសេសនៃការប្រើប្រាស់ បន្ទះការពារមូសខាំសំរាប់ព្យួរ ផើក ( PIRK)

## តើអ្វីទៅជា PIRK ?

មួយកញ្ចប់នៃ PIRK ត្រូវបានធ្វើជាត្បាញពីរសន្លឹកក្រដាស ចតុកោណ។ គេមើលវាដូចជាសន្លឹកក្រដា

## PIRK ធ្វើឡើងដើម្បីអ្វី ?

បន្ទះ PIRK ត្រូវបានបង្កើតឡើងសម្រាប់ការការពារ “bubble” ដែលមូសមិនចូលជិតអ្នក

## តើវិធីប្រើប្រាស់ PIRK យ៉ាងដូចម្តេច ?

បន្ទះ **PIRK** ដែលគេប្រើសម្រាប់ព្យួរលើជញ្ជាំង ឬពីលើដំបូល មិនតែប៉ុណ្ណឹងព្យួរកន្លែងខ្ពស់

ការព្យួរ PIRK ម្តងៗ វានឹងមានប្រសិទ្ធភាព (៣០ថ្ងៃ) ដែល មិនតម្រូវផ្លាស់ប្តូរវាទេ មិនចាំបាច់ធ្វើអ្វីទេ

## តើវាអាចត្រូវប្រើប្រាស់ជាមួយវិធីសាស្ត្រការការពារផ្សេងៗ បានយ៉ាងដូចម្តេច ?

អាចប្រើប្រាស់ ផើកនេះជាប់ជាមួយនឹងវិធីសាស្ត្រការការពារ ភ្នាក់ងារចំលងជំងឺទៃៗទៀតបានដោយគ្មានបញ្ហា



## តើអ្វីខ្លះដែលត្រូវធ្វើ ?

- មុខពេលប្រើ រក្សាទុកកន្លែងត្រជាក់ និងស្ងួតផុតពីពន្លឺព្រះអាទិត្យ  និងថង់ប្លាស្ទិចត្រូវបានខ្ចប់ទុករហូតដល់ថ្ងៃប្រើប្រាស់វា
- ពាក់ស្រោមដៃមុនពេលបើកកញ្ចប់ និងបើកកញ្ចប់លុះត្រាតែអ្នករៀបចំព្យួរ និងប្រើវា
- ព្យួរសន្លឹកក្រដាសនៅលើក្បាលរបស់អ្នកនៅខាងក្នុង ឬខាងក្រៅផ្ទះ ឬតាមលក្ខខណ្ឌក្នុងចំការ ឬក្នុងព្រៃ ឬក៏នៅលើដើមឈើ
- ព្យួរសន្លឹកក្រដាសនៅកន្លែងដែលមានមនុស្សចំណាយពេលច្រើននៅទីនោះ
- សន្លឹកក្រដាសត្រូវទុកដាក់ឱ្យផុតពីដៃក្មេង
- ប្រើសន្លឹកក្រដាសច្រើនតាមដែលអាចធ្វើបានទោះបីកន្លែងកំពុងប្រើមុងនិងងអង្រឹងជ្រលក់ថ្នាំ
- សំអាតដៃរបស់អ្នកជាមួយសាប៊ូ និងទឹក បន្ទាប់ពីព្យួរវា
- ផ្លាស់ប្តូរសន្លឹកក្រដាសមួយទៀត បន្ទាប់ពីបានប្រើប្រាស់វា អស់រយពេល៣០ថ្ងៃហើយ
- យកសន្លឹកក្រដាសទៅជាមួយអ្នក ដូចជាអ្នកផ្លាស់ទីពីផ្ទះចូលចំការ ព្រៃ ឬប៉ុស្តិ៍អភិរក្ស  និងពេលត្រឡប់មកវិញ ដែលប្រសិទ្ធភាពសន្លឹកក្រដាសអាចប្រើដោយសុវត្ថិភាពក្នុងកាលទេសៈផ្សេងៗគ្នា

## អ្វីខ្លះដែលមិនត្រូវធ្វើ ?

- ព្យួរបន្ទះក្រដាសផើកក្នុងកន្លែងដែលមិនមានមនុស្សនៅ (ឧទាហរណ៍ កន្លែងក្រោលសត្វនៅជាដើម)
- កុំព្យួរបន្ទះក្រដាសផើកនៅកន្លែងប៉ះផ្ទាល់នឹងពន្លឺព្រះអាទិត្យ ឬក៏ភ្លៀងក្នុងរយពេលយូរ
- ប្រើប្រាស់បន្ទះក្រដាសផើក ប្រសិនបើការវេចខ្ចប់ត្រូវបានបើកចំហមុនពេលដែលអ្នកបានរៀបចំរួចជាស្រេចក្នុងការប្រើប្រាស់វា
- កុំឱ្យបន្ទះក្រដាសផើកសើម ប្រសិនបើអ្នកកំពុងយកទៅព្រៃ ទុកដាក់ក្នុងថង់ប្លាស្ទិចការពារពីភ្លៀងសើម និងយកវាចេញពីថង់ពេលដែលអ្នករៀបចំប្រើប្រាស់វា
- កុំឱ្យវាទៅនរណាម្នាក់ក្រៅពីក្រុមគ្រួសារ ឬក្រុមអ្នកភិរក្សព្រៃឈើ

## អំពីសុវត្ថិភាពនៃការប្រើប្រាស់បន្ទះ ផើក PIRK )

- **PIRK** វាគ្មានក្លិន គ្មានផ្សួល!
- ការប៉ះផ្ទាស់ជាស្បែកអាចបង្ករជាកន្ទួល ឬក៏រមាស់បន្តិចបន្តួច
  - ប្រើប្រាស់ស្រោមដៃ ឬថង់ប្លាស្ទិច នៅពេលការកាន់វា (PIRK)
  - ប្រសិនបើអ្នកត្រូវបានរំខានពីកន្ទួល ឬរមាស់ សូមទៅពិគ្រោះនៅមណ្ឌលសុខភាពនៅក្បែរ សញ្ញាទាំងនេះនឹងបាត់ទៅវិញឆាប់ៗ
- សូមរក្សាទុកបន្ទះនេះ (PIRK) ឱ្យផុតពីដៃក្មេង
- បន្ទាប់ពីព្យួរក្រដាសផើក (PIRK) សូមលាងដៃអ្នកជាមួយនឹងសាប៊ូ និងទឹក

# លក្ខខណ្ឌពិសេសនៃការប្រើប្រាស់ ថ្នាំបាញ់លើស្បែកការពារមូសខាំ ( Topical Repellent)

## តើអ្វីទៅថ្នាំបាញ់លើស្បែកការពារមូសខាំ ?

ស្រ្តាយរាងថ្លាដែលចេញពីកំប៉ុងប្លាស្ទីចតូចជាមួយបំពងចុចចង្អុលដៃ ដែលផ្ទុករួមមាន ២0%នៃ Picaridin ឬ ១៥% នៃ DEET

## តើធ្វើថ្នាំបាញ់លើស្បែកការពារមូសខាំឡើងដើម្បីអ្វី ?

បន្ទាប់ពីការបាញ់ការពារលើស្បែកខ្លួនប្រាណ មូសត្រូវបានបណ្តេញពីការទុំ និងខាំលើខ្លួនរបស់អ្នក

## តើវិធីប្រើប្រាស់វាយ៉ាងដូចម្តេច ?

វាត្រូវបានបាញ់លើស្បែក ហើយវាមានប្រសិទ្ធភាព លើសពី ៨ ម៉ោង

## តើវាអាចត្រូវប្រើប្រាស់ជាមួយវិធីសាស្រ្តការការពារផ្សេងបានយ៉ាងដូចម្តេច ?

អាចប្រើប្រាស់ថ្នាំនេះជាប់ជាមួយនឹងវិធីសាស្រ្តការការពារដ៏ទៃទៀតដោយគ្មានបញ្ហា



## តើអ្វីខ្លះដែលត្រូវធ្វើ

- សូមរក្សាទុកកន្លែងត្រជាក់ ហើយស្ងួត មិនឱ្យត្រូវពន្លឺព្រះអាទិត្យរហូតដល់ពេលប្រើប្រាស់
- បាញ់តែទៅលើស្បែកប៉ុណ្ណោះ
- ការប្រើប្រាស់ថ្នាំនេះដែលរួមបញ្ចូលគ្នាជាមួយវិធីសាស្រ្តបង្ការមូសខាំ ដូចមានជ្រលក់ថ្នាំសម្លៀកបំពាក់ និងក្រដាសសន្លឹកព្យួរលើជញ្ជាំង
- បាញ់ថ្នាំនេះបានរហូតដល់២ដង ក្នុងមួយថ្ងៃ ពេលដែលអ្នកមិនកំពុងសំរាន ឬសម្រាកនៅលើគ្រែ ឬក្នុងមុង
- សូមរក្សាដបថ្នាំនេះផុតពីដៃក្មេងៗ

## អ្វីខ្លះដែលមិនត្រូវធ្វើ

- កុំបាញ់ចូលភ្នែក ឬមាត់
- កុំផ្តល់ថ្នាំនេះទៅមនុស្សក្រៅពីគ្រួសាររបស់អ្នក ឬក៏ក្រុមអ្នកអភិរក្ស

## អំពីសុវត្ថិភាព សម្រាប់ការប្រើប្រាស់ថ្នាំបាញ់ការពារមូសខាំ

- ថ្នាំបាញ់ការពារមូសខាំមានក្លិនផ្អែមបន្តិច តែក្លិននេះគឺមិនបង្ករគ្រោះថ្នាក់អ្វីឡើង
- ចៀសវាងកុំបាញ់ចំភ្នែក និងមាត់
- សូមទុកដាក់ថ្នាំនេះឱ្យផុតពីដៃក្មេង
- អាចបាញ់បាន២ដងក្នុងមួយថ្ងៃដែលមានប្រសិទ្ធភាពបាន៨ម៉ោង

# លក្ខខណ្ឌពិសេសនៃប្រើប្រាស់ផលិផល សម្រាប់ការជ្រលក់ថ្នាំលើសម្លៀកបំពាក់ (Etofenprox)

## អ្វីទៅជាថ្មីជ្រលក់សំលៀកបំពាក់ ?

ថ្នាំជ្រល់សម្លៀកបំបាក់អាចប្រើប្រាស់ លើសពីសម្លៀកបំពាក់ ដូចជាក្រម៉ាជាដើម ក៏អាចជ្រលក់បានដែរ

## តើប្រើប្រាស់ថ្នាំនេះដើម្បីអ្វី ?

ថ្នាំជ្រលក់សម្លៀកបំពាក់នេះ មិនមានន័យថាប្រើប្រាស់ដើម្បី បណ្តេញមូសទេ តែផ្ទុយទៅវិញ វាអាចសំលាប់មូសនៅពេល មូសនោះមកប៉ះពាល់នឹងសម្លៀកបំបាក់ដែលបានជ្រលក់ថ្នាំ រួចរាល់ហើយ។

## តើយើងប្រើប្រាស់វារបៀបណា ?

សម្លៀកបំពាក់ដែលបានបាញ់ ឬជ្រលក់រួចរាល់ហើយ គឺអាច ប្រើប្រាស់ ស្លៀកពាក់បានដូច សម្លៀកបំពាក់ដែលមិនបាន ប្រើប្រាស់ថ្នាំនោះដែរ។ សម្លៀកបំពាក់ដែលបានជ្រលក់ាឬ បាញ់ជាមួយ etofenproxរួចគឺអាចបោកគក់ដល់ទៅ២៥ដង

## តើវាអាចប្រើប្រាស់រួមគ្នាជាមួយសំភារៈការពារមូស ដទៃទៀតបានដែរឬទេ ?

គឺយើងអាចប្រើប្រាស់ជាមួយសំភារៈការពារមូសដទៃទៀត បានដោយងាយ និងមិនមានបញ្ហាដែរ។



## តើអ្វីខ្លះដែលត្រូវធ្វើ

- ស្លៀកពាក់សម្លៀកបំពាក់ដែលជ្រលក់ថ្នាំហើយ គឺ ពាក់ធម្មតាដូចខោអាវដទៃទៀតផងដែរ
- អ្នកត្រូវប្រាកដថាត្រូវតែស្លៀកពាក់សម្លៀកបំបាក់ ដែលជ្រលក់ថ្នាំរួចគឺពាក់រាល់ការចូលក្នុងព្រៃ ពាក់ នៅខាងក្រៅកន្លែងផ្សេង មិនបាច់ស្លៀកពាក់នៅ នៅពេលគេងនៅក្នុងមុខជ្រលក់ថ្នាំ និង មុខអង្រឹង នោះទេ
- សម្លៀកបំពាក់ដែលបានជ្រលក់ថ្នាំហើយ មិនតំរូវ អោយយើងមានលក្ខ័ណការពារទុកដាក់ ដូចទៅ នឹងសម្លៀកបំបាក់ផ្សេងទៀតនោះទេ
- ត្រូវធានាថាទឹកដែលបោកគក់ខោអាវដែលយើង បានជ្រលក់ថ្នាំនៅត្រូវចាក់ចោលនៅឆ្ងាយពីប្រភព ទឹកប្រើប្រាស់ របស់មនុស្សនិង សត្វ
- បើសម្លៀកបំពាក់ដែលជ្រលក់រួចថ្មីមានខ្លិនមិនល្អ អ្នកអាចយកទៅបោកគក់ម្តងមុនស្លៀកពាក់បាន។

## អ្វីខ្លះដែលមិនត្រូវធ្វើ

- មិនអនុញ្ញាតអោយមនុស្សនៅខាងក្រៅគ្រួសាររបស់ អ្នក ឬ អ្នកភិរក្សប្រើប្រាស់សម្លៀកបំពាក់ដែលជ្រលក់ ថ្នាំរួចរបស់អ្នកនោះទេ។ ពួកគាត់មិនដែលទទួលបាន ការណែនាំវិធីការប្រើប្រាស់ដូចអ្នកនោះទេ
- កុំបោកសម្លៀកបំពាក់តាមប្រឡាយ ឬស្ទឹង ឬក៏ប្រភព ទឹកផ្សេងៗដែលវាអាចជាទឹកសម្រាប់បរិភោគ ឬជម្រក សត្វក្នុងទឹក។

## អំពីសុវត្ថិភាពសម្រាប់ថ្នាំជ្រលក់សម្លៀកបំពាក់

- ការជ្រលក់ថ្នាំក្នុងសម្លៀកបំពាក់វាអាចមានក្លិន ហើយ ក្លិននេះវាមិនបង្កភាពគ្រោះថ្នាក់ទេ និងវានឹងរលាយនៅ ពេលស្លៀកពាក់វា និងបោកសម្លៀកបំពាក់
- អ្នកនឹងទទួលការកន្ទួល ឬរមាស់បន្តិចបន្តួចពេលអ្នក ស្លៀកពាក់ជ្រលក់ថ្នាំជាលើកដំបូង ប៉ុន្តែអ្នកអាចបោក សម្លៀកបំពាក់នេះវាអាចជួយឱ្យមានការបន្ថយនូវភាព រំខាននេះ
- ការបោកសម្លៀកបំពាក់ដែលបានជ្រលក់ថ្នាំរួចគឺត្រូវធ្វើ ឡើងតាមការណែនាំ